អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
## ការតែងតាំងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ និងសហព្រះរាជអាជ្ញារងអន្តរជាតិថ្មី

បន្ទាប់ពីត្រូវបានចាត់តាំងដោយឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ (អ.ស.ប) និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លោកអូលីវីយេ បូវ៉ាល់ឡេ (ជនជាតិបារាំង)ត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិថ្មីនៅអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ លោកចៅក្រម បូវ៉ាល់ឡេ ត្រូវបំពេញតួនាទីជំនួសលោកចៅក្រម ចាងហូ ជុង (ជនជាតិកូរ៉េខាងត្បូង) ដែលបានលាលែងពីតំណែងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៥។

នាពេលថ្មីៗនេះ លោកចៅក្រម បូវ៉ាល់ឡេ បានបំពេញតួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៃអ.វ.ត.ក។ លោកធ្លាប់បានបំពេញការងារជារដ្ឋអាជ្ញាពិសេស នៅក្នុងការិយាល័យអយ្យការពិសេសនៃបេសកកម្ម EULEX នៅក្នុងប្រទេសកូសូវ៉ូ ដែលនៅទីនោះលោកមានបទពិសោធន៍ធ្វើការងារលើរឿងក្តីជាច្រើនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយមានការរៀបចំ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើភេរវកម្ម។ ពីមុនមក លោក អូលីវីយេ ធ្លាប់បម្រើការងារជាចៅក្រមស៊ើបអង្កេតនៅប្រទេសបារាំងនៅក្នុងសំណុំរឿងទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានការរៀបចំ មានមូលដ្ឋាននៅ French West Indies (តុលាការពិសេសសម្រាប់ឧក្រិដ្ឋកម្មដោយមានការរៀបចំ នៅ Fort-de-France)។ លោកបានចូលរួមក្នុងគម្រោងអន្តរជាតិមួយចំនួននៅតំបន់បាល់កង់ ទ្វីបអាហ្វ្រិក និងអាស៊ីកណ្តាល។

ដោយឡែក បន្ទាប់ពីត្រូវបានចាត់តាំងដោយឯកឧត្តម បាន គីមូន អគ្គលេខាធិការ អ.ស.ប និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លោកស្រីប្រេនដា ហូលីស (ជនជាតិអាមេរិក) ត្រូវបានតែងតែងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងនៅអ.វ.ត.ក។ តំណែងនេះបាននៅទំនេរចាប់តាំងពីមានការតែងតាំងលោកនីខូឡាស គុំជៀន (ជនជាតិអាមេរិក) ជាសហព្រះរាជអាជ្ញាអន្តរជាតិនៅឆ្នាំ ២០១៣។ ពីមុន លោកស្រី ហូលីស ធ្លាប់បម្រើការងារជារដ្ឋអាជ្ញានៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។ លោកស្រី ក៏ធ្លាប់បម្រើការងារជារដ្ឋអាជ្ញាជាន់ខ្ពស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (0) ២៣ ៨៦១ ៦៦៩
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
ទូរស័ព្ទ: +៨៥៥ (0) ២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh